**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៤៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងកម្រិតប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



https://www.moj.gov.kh/kh/law-regular

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងកម្រិតប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតនិវាសនជន និងប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំរបស់សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល។

**មាត្រា៣ .-**

១- កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែនិងអត្រាពន្ធសម្រាប់និយោជិតនិវាសនជន ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ (គិតជារៀល) | | | | អត្រាពន្ធ |
|---|---|---|---|---|---|
| ១ | ពី | ០ | ដល់ | ១ ៥០០ ០០០ | ០% |
| ២ | ពី | ១ ៥០០ ០០១ | ដល់ | ២ ០០០ ០០០ | ៥% |
| ៣ | ពី | ២ ០០០ ០០១ | ដល់ | ៨ ៥០០ ០០០ | ១០% |
| ៤ | ពី | ៨ ៥០០ ០០១ | ដល់ | ១២ ៥០០ ០០០ | ១៥% |
| ៥ | | | លើសពី | ១២ ៥០០ ០០០ | ២០% |

២- ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារ និយោជិតនិវាសនជនត្រូវបានទទួលនូវការកាត់បន្ថយមូលដ្ឋានកំណត់ពន្ធដូចខាងក្រោម៖

ក- កូនស្ថិតក្នុងបន្ទុកចំនួន ១៥០ ០០០ រៀល ក្នុងកូនម្នាក់ៗក្នុងមួយខែ។

ខ- សហព័ទ្ធដែលធ្វើតែជាមេផ្ទះចំនួន ១៥០ ០០០ រៀល សម្រាប់តែម្នាក់ក្នុងមួយខែ។

ក្នុងករណីសហព័ទ្ធក្នុងគ្រួសារបម្រើការងារទាំងពីរនាក់ ការកាត់បន្ថយដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌនេះត្រូវបានផ្ដល់ឱ្យតែសហព័ទ្ធម្នាក់ប៉ុណ្ណោះ។

**មាត្រា៤ .-**

កម្រិតប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំនិងអត្រាពន្ធសម្រាប់សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | កម្រិតប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ (គិតជារៀល) | | | | អត្រាពន្ធ |
|---|---|---|---|---|---|
| ១ | ពី | ០ | ដល់ | ១៨ ០០០ ០០០ | ០% |
| ២ | ពី | ១៨ ០០០ ០០១ | ដល់ | ២៤ ០០០ ០០០ | ៥% |
| ៣ | ពី | ២៤ ០០០ ០០១ | ដល់ | ១០២ ០០០ ០០០ | ១០% |
| ៤ | ពី | ១០២ ០០០ ០០១ | ដល់ | ១៥០ ០០០ ០០០ | ១៥% |
| ៥ | | | លើសពី | ១៥០ ០០០ ០០០ | ២០% |



https://www.moj.gov.kh/kh/law-regular

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular